លឹម ផល្គុន និង សែន ពិសិដ្ឋ
បរិញ្ញាត្រផ្នែកគណិតវិទ្យា

# គណិតវិទ្យាជុំវិញពិភពលោក

សម្រាប់

សិស្សពូកែផ្នែកគណិតវិទ្យា

ត្រៀមប្រឡងអាហារូបករណ៍

## ភាគ៨

$$f([x]y)=f(x)\,[f(y)]$$

រក្សាសិទ្ធិ

## គណៈកម្មការនិពន្ធ និង រៀបរៀង

លឹម ផល្គុន និង សែន ពិសិដ្ឋ

## គណៈកម្មការត្រួតពិនិត្យបច្ចេកទេស

| | |
|---|---|
| លោក លឹម ឆុន | លោក អ៊ឹង សំណាង |
| លោក នន់ សុខណា | លោកស្រី ទុយ រីណា |
| លោក ព្រឹម សុនិត្យ | លោក ផល ប៊ុនឆាយ |
| លោក និត្យ ម៉េង | |

## គណៈកម្មការត្រួតពិនិត្យអក្ខរាវិរុទ្ធ

លោក លឹម មិគ្គសិរ

## ការីកុំព្យូទ័រ

កញ្ញា លី គុណ្ណាភា លោក អ៊ឹង សំណាង

# អារម្ភកថា

សៀវភៅគណិតវិទ្យាជុំវិញពិភពលោកភាគទី៨ ដែលអ្នកសិក្សាកំពុងកាន់នៅក្នុងដៃនេះ ចែកចេញជាបីផ្នែកដែលផ្នែកទី១ ជាកម្រងលំហាត់ជ្រើសរើស ផ្នែកទី២ ជាផ្នែកដំណោះស្រាយ និង ផ្នែកទី៣ ជាលំហាត់អនុវត្តន៍ ។ រាល់បប្រធានលំហាត់នីមួយៗនៅក្នុងសៀវភៅនេះ យើងខ្ញុំបានជ្រើសរើសយកតែ លំហាត់ណាដែលមានលក្ខណៈពិបាក មកធ្វើដំណោះស្រាយគំរូយ៉ាងក្បោះក្បាយបំផុត ។

គោលបំណងនៃការរៀបរៀងចងក្រងគឺដើម្បីទុកជាឯកសារជំនួយសម្រាប់អ្នកសិក្សាក្នុងគ្រប់មជ្ឈដ្ឋាន និង ម្យ៉ាងទៀតដើម្បីចូលរួមលើកស្ទួយវិស័យគណិតវិទ្យាក្នុងប្រទេសកម្ពុជាយើងឱ្យកាន់តែរីកចម្រើនឆាប់រហ័ស្របតាមសម័យវិទ្យាសាស្ត្រទំនើប ។

សៀវភៅនេះមិនល្អហួសគេហួសឯងនោះទេ ។ កំហុសឆ្គងដោយអចេតនាប្រាកដជាមានទាំងបច្ចេកទេស និង អក្ខរាវិរុទ្ធ ។ ហេតុនេះយើងខ្ញុំជាអ្នកនិពន្ធ រងចាំជានិច្ចនូវមតិរិះគន់បែបស្ថាបនាពីអ្នកសិក្សាគ្រប់មជ្ឈដ្ឋានដោយក្ដីរីករាយដើម្បីកែលំអសៀវនេះឱ្យកាន់តែមានសុក្រិត្យភាពប្រសើរឡើងថែមទៀត ។

ជាទីបញ្ចប់ ខ្ញុំបាទអ្នកនិពន្ធសូមគោរពជូនពរអ្នកសិក្សាទាំងអស់មានសុខភាពល្អ មានប្រាជ្ញាឈ្លាសវៃ និង ទទួលបានជោគជ័យជានិច្ចក្នុងការសិក្សា ។

បាត់ដំបង ថ្ងៃទី ២៧ ខែធ្នូ ឆ្នាំ២០១០

អ្នកនិពន្ធ និង ស្រាយជ្រាវ **លឹម ផល្គុន**
**Tel : 017 768 246**
**Email: lim_phalkun@ymail.com**
**Website: www.mathtoday.wordpress.com**

# កម្រងលំហាត់

1. ចូរកំណត់គ្រប់អនុគមន៍ $\mathbf{f:\ IR \to IR}$ ដោយដឹងថាសមភាព

$\mathbf{f(\lfloor x \rfloor y) = f(x) \lfloor f(y) \rfloor}$ ពិតជានិច្ចគ្រប់ $\mathbf{x, y \in IR}$ ។

( $\lfloor \mathbf{a} \rfloor$ តាងឱ្យផ្នែកគត់នៃ $\mathbf{a}$ ) ។ ( IMO 2010 )

2. ចំពោះគ្រប់ចំនួនពិត $x \in (0, \frac{\pi}{2})$

ចូរស្រាយថា $\dfrac{\sqrt{3}}{\sin x} + \dfrac{1}{\cos x} \ge 2 + \sqrt{3}$ ។

3. ដោះស្រាយសមីការ :

$$6 + \log_{\frac{1}{3}}(1 + 2^x) + \log_3{}^2(1 + 2^x) = 2\sqrt{8 + \log_3{}^3(1 + 2^x)}$$

4. គេមានអនុគមន៍ $f(x) = \dfrac{x+4}{x+1}$ ដែល $x \ne -1$ ។

គណនា $f_n[f[...f[f(x)]...]]$

5. គេឱ្យអនុគមន៍ $f(x) = \dfrac{1}{a + b\sin^2 x} + \dfrac{1}{c + b\cos^2 x}$

ដែល $a > 0$ , $b > 0$ ។

ចូរបង្ហាញថា $f(x) \ge \dfrac{4}{a+b+c}$ ចំពោះគ្រប់ចំនួនពិត $x$ ។

6. គេមានស្វ៊ីត $(x_n)$ និង $(y_n)$ កំណត់ដោយ $\begin{cases} x_0 = 1 \\ y_0 = 0 \end{cases}$ និង

$$\begin{cases} x_{n+1} = \frac{1}{2}(\sin a + \cos a)x_n + \frac{1}{2}\sin a(1 - \tan a)y_n \\ y_{n+1} = \frac{1}{2}\cos a(\cot a - 1)x_n + \frac{1}{2}(\sin a + \cos a)y_n \end{cases}$$

ដែល $0 < a < \frac{\pi}{2}$ និង $n = 0, 1, 2, ....$ ។

ក. ចំពោះគ្រប់ $n \geq 0$ តាង $u_n = x_n \cos a + y_n \sin a$ និង

$v_n = x_n \cos a - y_n \sin a$ ។

ចូរស្រាយថា $(u_n)$ និង $(v_n)$ សុទ្ធតែជាស្វ៊ីតធរណីមាត្រ ។

ខ.គណនា $u_n$ និង $v_n$ ជាអនុគមន៍នៃ $n$ និង $a$ ។

គ. ទាញរក $x_n$ និង $y_n$ ជាអនុគមន៍នៃ $n$ និង $a$ ។

7. គេឱ្យអនុគមន៍ $f$ កំណត់គ្រប់ $x \in IR$ ដោយទំនាក់ទំនង :

$$f(x) + \sqrt{2} f(\frac{\pi}{4} - x) = \sin x + 3\cos x$$

ចូរស្រាយថា $| f(x) | \leq \sqrt{2}$ គ្រប់ $x \in IR$ ។

8. គេឱ្យអនុគមន៍ $f$ កំណត់គ្រប់ $x \in IR$ ដោយទំនាក់ទំនង :

$$2f(\frac{\pi}{2}-x)+f(\frac{\pi}{2}+x)=\sin x+3\sqrt{3}\cos x$$

កំណត់ចំនួនពិត $r$ និង $\varphi$ ដើម្បីឱ្យអនុគមន៍ $f(x)$ អាចសរសេរ :

$f(x)=r\sin(x+\varphi)$ គ្រប់ $x \in IR$ ។

9.គេឱ្យអនុគមន៍ $f$ កំណត់គ្រប់ $x \in IR$ ដោយទំនាក់ទំនង :

$$5f(x)-3\sin x\, f(\pi-x)=4\cos x$$

ចូររកតម្លៃតូចបំផុត និង ធំបំផុតនៃ $f(x)$

10. គេឱ្យអនុគមន៍ $f$ និង $g$ កំណត់គ្រប់ $x \in IR$ ដោយទំនាក់ទំនង :

$$\begin{cases} f(x)+g(\frac{\pi}{2}-x)=2\sin x \\ 3f(\frac{\pi}{2}-x)-g(x)=2\cos x \end{cases}$$

ចូររកអនុគមន៍ $f(x)$ និង $g(x)$

11. គេឱ្យអនុគមន៍ $f$ កំណត់គ្រប់ $x \in (-1,1)$ ដោយទំនាក់ទំនង :

$$f(x)-2f(-x)=\ln(\frac{1-3x+3x^2-x^3}{1+3x+3x^2+x^3})$$

ចូររក $f(\cos\theta)$ ជាអនុគមន៍នៃ $t=\tan\frac{\theta}{2}$ ។

12. គេឱ្យអនុគមន៍ $f$ កំណត់គ្រប់ $x \in IR$ ដោយទំនាក់ទំនង :

$$f(x)+3f(-x)+8=4(e^{\frac{x}{2}}+e^{-\frac{x}{2}})^2$$

ចូរគណនាលីមីត $\lim\limits_{x\to 0}\frac{f(x)-2}{x^2}$

13. គេឱ្យអនុគមន៍ $\mathbf{f:IR \mapsto IR}$ កំណត់ដោយទំនាក់ទំនង :

$$\begin{cases} f(1)=-2 \\ (x-y)f(x+y)-(x+y)f(x-y)=4xy(x^2-y^2) \end{cases}$$

ក. កំណត់រកអនុគមន៍ $\mathbf{f(x)}$

ខ. កំណត់ $\mathbf{x}$ ដើម្បីឱ្យ $\mathbf{f(x)=\sqrt{3}}$ ។

14. ចំពោះ $\mathbf{a}$ និង $\mathbf{b}$ ជាចំនួនពិត សមីការ

$\mathbf{x^4+ax^3+bx^2+ax+1=0}$ មានឫសយ៉ាងតិច

មួយជាចំនួនពិត ។

ចូរគណនាតម្លៃតូចបំផុតនៃ $\mathbf{a^2+b^2}$ ? $\mathbf{(IMO\ \ 1973)}$

15. គេឱ្យអនុគមន៍លេខ $\mathbf{f}$ កំនត់ដោយទំនាក់ទំនង :

$\mathbf{f(1)=\frac{7}{5}}$ និង $\mathbf{f(n+1)=\frac{13f(n)-16}{9f(n)-11}}$ ដែល $\mathbf{n=1,2,3,...}$

ចូរស្រាយថា $\mathbf{f(n)}$ ជាប្រភាគសម្រួលមិនបាន ។

16. គេឱ្យស៊ីតនៃចំនួនពិត $\mathbf{(u_n)}$ កំណត់ដោយ :

$u_1 = \frac{7}{2}$ និង $u_{n+1} = {u_n}^2 + u_n - \frac{1}{4}$ គ្រប់ $n \geq 1$

បង្ហាញថាគេអាចកំណត់ចំនួនពិត $a$ ដែល $u_{n+1} + a = (u_n + a)^2$

ចំពោះគ្រប់ $n \geq 1$ រួចគណនា $u_n$ ជាអនុគមន៏នៃ $n$ ។

17. គេឱ្យចំនួនកុំផ្លិច $z = \sqrt{2+\cos\varphi} + i\sqrt{2+\sin\varphi}$

ដែល $\varphi \in IR$ ។

ក្នុងប្លង់កំផ្លិច $(o, \vec{i}, \vec{j})$ គេហៅ $M$ ជាចំនុចរូបភាពនៃ $z$ ។

ចូរកំណត់តម្លៃតូចបំផុត និង ធំបំផុតនៃ $r = OM$ ?

18. គេឱ្យចំនួនកុំផ្លិច $z_1, z_2, z_3$ ហើយផ្ទៀងផ្ទាត់ទំនាក់ទំនង :

$$|z_1| = |z_2| = |z_3| = 1 \text{ និង } \frac{{z_1}^2}{z_2 z_3} + \frac{{z_2}^2}{z_1 z_3} + \frac{{z_3}^2}{z_1 z_2} + 1 = 0$$

ចូរស្រាយថា $|z_1 + z_2 + z_3| \in \{1, 2\}$ ។

19.គេឱ្យចំនួនកុំផ្លិច $z_1$ និង $z_2$ ដែល $|z_1| = |z_2| = 1$

ចូរស្រាយថា $|z_1 + 1| + |z_2 + 1| + |z_1 z_2 + 1| \geq 2$

20. គេឱ្យស្វ៊ីតចំនួនពិត $(a_n)$ កំណត់ដោយ :

$$\begin{cases} a_1 = 1 , a_2 = 1 \\ a_{n+2} = a_{n+1} - a_n \ \ , n = 1 , 2 , 3 ,... \end{cases}$$

គេតាងស្វ៊ីតចំនួនកុំផ្លិច $z_n = a_{n+1} - \frac{1 - i\sqrt{3}}{2} a_n$ ។

ក. ចូរស្រាយថា $z_{n+1} = \frac{1 + i\sqrt{3}}{2} z_n$ ចំពោះគ្រប់ $n \geq 1$ ។

ខ. ចូរដាក់ $\frac{1 + i\sqrt{3}}{2}$ ជាទម្រង់ត្រីកោណមាត្ររួចទាញរក $z_n$ ជាអនុគមន៏

នៃ $n$ ។

គ. ទាញរកតួទូទៅនៃស្វ៊ីត $a_n$ ។ តើ $(a_n)$ ជាស្វ៊ីតខួបឬទេ ?

21. គេឱ្យស្វ៊ីតនៃចំនួនកុំផ្លិច $(z_n)$ កំណត់ដោយ :

$$z_1 = \frac{2 + \sqrt{3} + i}{2} \ \text{និង}\ z_{n+1} = \frac{\sqrt{3} + i}{2} z_n + \frac{2 - \sqrt{3} - i}{2}$$

ដែល $n = 1 , 2 ,3 ,...$ ។

ក. តាង $w_n = z_n - 1$ ។ បង្ហាញថា $(w_n)$ ជាស្វ៊ីតធរណីមាត្រនៃចំនួន

កុំផ្លិច រួចគណនា $w_n$ ជាអនុគមន៏នៃ $n$ ដោយសរសេរលទ្ធផលជាទម្រង់

ត្រីកោណមាត្រ ។

ខ. ទាញបង្ហាញថា $z_n = 2\cos\frac{n\pi}{12}(\cos\frac{n\pi}{12} + i\sin\frac{n\pi}{12})$ ។

22. គេឱ្យស្ទីតនៃចំនួនពិត $(u_n)$ និង $(v_n)$ កំណត់ដោយ :

$$\begin{cases} u_1 = \dfrac{\sqrt{2}}{2} \\ v_1 = \dfrac{\sqrt{2}}{2} \end{cases} \quad \text{និង} \quad \begin{cases} u_{n+1} = \dfrac{u_n - v_n}{\sqrt{2}} \\ v_{n+1} = \dfrac{u_n + v_n}{\sqrt{2}} \end{cases} \quad \text{ដែល } n \geq 1$$

ក. គេពិនិត្យស្ទីតនៃចំនួនកុំផ្លិច $z_n = u_n + i.v_n$ ។

ចូរស្រាយថា $(z_n)$ ជាស្ទីតធរណីមាត្រនៃចំនួនកុំផ្លិច រួចគណនា $z_n$ ជាអនុគមន៍នៃ $n$ ដោយសរសេរលទ្ធផលជាទម្រង់ត្រីកោណមាត្រ ។

ខ. សំដែង $u_n$ និង $v_n$ ជាអនុគមន៍នៃ $n$ ។

23. គេឱ្យស្ទីតនៃចំនួនពិត $(u_n)$ និង $(v_n)$ កំណត់ដោយ :

$$\begin{cases} u_0 = 1 \\ v_0 = \sqrt{3} \end{cases} \quad \text{និង} \quad \begin{cases} u_{n+1} = {u_n}^2 - {v_n}^2 \\ v_{n+1} = 2u_n v_n \end{cases} \quad \text{ដែល } n \geq 0$$

ក. គេពិនិត្យស្ទីតនៃចំនួនកុំផ្លិច $z_n = u_n + i.v_n$ ។

ចូរស្រាយថា $z_{n+1} = {z_n}^2$ រួចទាញថា $z_n = {z_0}^{2^n}$ ។

ខ. សំដែង $u_n$ និង $v_n$ ជាអនុគមន៍នៃ $n$ ។

24. គេឱ្យស្វ៊ីតនៃចំនួនពិត $(I_n)$ កំណត់ដោយ :

$$I_0=\int_0^1\frac{dx}{1+e^x}\ ,\ I_1=\int_0^1\frac{e^x dx}{1+e^x},...,I_n=\int_0^1\frac{e^{nx}}{1+e^x}.dx$$

ដែល $n$ ជាចំនួនគត់ធម្មជាតិ ។

ក. គណនា $I_0+I_1;I_1$ រួចទាញរកតម្លៃនៃ $I_0$ ។

ខ. គណនា $I_n+I_{n+1}$ ជាអនុគមន៍នៃ $n$ រួចទាញរកតម្លៃ $I_2$ និង $I_3$ ។

គ. ចំពោះ $x\in[0,1]$ ចូរប្រៀបធៀបតម្លៃ $e^{nx}$ និង $e^{(n+1)x}$ ។

បង្ហាញថា $(I_n)$ ជាស្វ៊ីតកើន ដោយមិនចាំបាច់គណនា $I_n$ ។

ឃ. បង្ហាញថាចំពោះគ្រប់ $x\in[0,1]$ គេមាន $\frac{1}{4}\le\frac{1}{1+e^x}\le\frac{1}{2}$

រួចទាញរកកន្សោមអមនៃ $I_n$ តាមការគណនា $\int_0^1 e^{nx}.dx$ ។

តើស្វ៊ីត $(I_n)$ មានលីមីតឬទេ ?

25. គេឱ្យស្វ៊ីត $I_n=\int_0^1\frac{x^n}{1+x+x^2}.dx$ ដែល $n\ge 0$

ក. បង្ហាញថា $(I_n)$ ជាស្វ៊ីតចុះ ។

ខ. គណនា $I_n+I_{n+1}+I_{n+2}$ ជាអនុគមន៍នៃ $n$ ។

គ. ចូរស្រាយថា $\frac{1}{3(n+1)}\le I_n\le\frac{1}{3(n-1)}$ ចំពោះ $n\ge 2$

រួចទាញរក លីមីត $\lim\limits_{n\to+\infty} nI_n$ ។

26. គណនាអាំងតេក្រាល $I=\int_0^{\pi} x\sin x\cos^6 x.dx$

27. គណនាអាំងតេក្រាល $I=\int_0^1 \frac{x^2-1}{x^4+1}.dx$

28. គេឱ្យអាំងតេក្រាល $I_n=\int_0^a \frac{x^4dx}{x^n+a^n}$ ដែល $a>0$ ។

កំណត់ $n$ ដើម្បីឱ្យ $I_n$ មិនអាស្រ័យនឹង $a$ រួចគណនា $I_n$ ចំពោះតម្លៃនៃ $a$ ដែលបានរកឃើញខាងលើ ។

29. គេឱ្យអាំងតេក្រាល $I_n=\int_0^a \frac{x^n dx}{\sqrt{x^4+a^4}}$ ដែល $a>0$ ។

កំណត់ $n$ ដើម្បីឱ្យ $I_n$ មិនអាស្រ័យនឹង $a$ រួចគណនា $I_n$ ចំពោះតម្លៃនៃ $a$ ដែលបានរកឃើញខាងលើ ។

30. ចូរស្រាយថា $\left|\int_0^1 \frac{a\cos x+b\sin x}{1+x^2}.dx\right|\le\frac{\pi}{4}\sqrt{a^2+b^2}$

ដែល $a$ និង $b$ ជាពីរចំនួនពិត ។

31. គេឱ្យស្វ៊ីត $(u_n)$ នៃចំនួនពិតកំនត់លើ $IN^*$ ដោយ :

$$u_n = \frac{1}{n(n+1)(n+2)}$$ ។

ក. កំនត់ចំនួនពិត $A, B, C$ ដើម្បីឱ្យ

$$\frac{1}{n(n+1)(n+2)} = \frac{A}{n} + \frac{B}{n+1} + \frac{C}{n+2}$$ ។

ខ. តាង $S_n = u_1 + u_2 + u_3 + .... + u_n$ ។

គណនា $\lim_{n\to+\infty} S_n$ ។

គ. ចំពោះគ្រប់ $n \in IN^*$ គេតាង $V_n = u_n - \int_n^{n+1} g(x).dx$

ដែល $g$ ជាអនុគមន៏កំនត់ដោយ $g(x) = \frac{1}{x(x+1)(x+2)}$

និង $S'_n = V_1 + V_2 + V_3 + ... + V_n$ ។

ចូរបង្ហាញថា $S'_n = S_n - \int_1^{n+1} g(x).dx$ ហើយទាញរក $S'_n$

និង $\lim_{n\to+\infty} S'_n$ ។

32. គណនាអាំងតេក្រាល :

$$I=\int_{\frac{\pi}{6}}^{\frac{\pi}{3}}\frac{\sin^n x}{\sin^n x+\cos^n x}.dx$$ និង $$I=\int_{\frac{\pi}{6}}^{\frac{\pi}{3}}\frac{\sin^n x}{\sin^n x+\cos^n x}.dx$$

33. គេឱ្យ $f$ ជាអនុគមន៍កំនត់ក្នុងចន្លោះ $[\,0\,;\pi]$

ក. ចូរបង្ហាញថា $\int_0^{\pi}xf(\sin x).dx=\frac{\pi}{2}\int_0^{\pi}f(\sin x).dx$

ខ. អនុវត្តន៍ ចូរគណនា $I=\int_0^{\pi}\frac{x\sin x}{1+\cos^2 x}.dx$

34. គេឱ្យអនុគមន៍ $f$ កំនត់លើ $[a\,;b]$

ដែល $\forall x\in[a\,;b]:\ f(a+b-x)=f(x)$ ។

ចូរបង្ហាញថា $\int_a^b xf(x).dx=\frac{a+b}{2}\int_a^b f(x).dx$ ។

អនុវត្តន៍

ចូរគណនា $I=\int_0^{\pi}\frac{x\sin x}{\sqrt{3-\cos 2x}}.\,dx$ ។

35. គេឱ្យអនុគមន៍ $f(x)=\frac{\ln(1+x)}{1+x^2}$ , $x>-1$

ក. បង្ហាញថា $f(\frac{1-t}{1+t})=\frac{1}{2}\frac{(1+t)^2}{1+t^2}-\frac{1}{2}(1+t)^2 f(t)$ ដែល $0\le t\le 1$ ។

ខ. គណនា $I=\int_{0}^{1} f(x).dx$ ។

គ. ទាញរកតម្លៃ $J=\int_{0}^{1}\frac{\arctan x}{1+x}.dx$ ។

36. គេមានស្វ៊ីត $(I_n)$ កំនត់ចំពោះគ្រប់ $n\ge 1$ ដោយ :

$$I_n=\frac{1}{n!}.\int_{0}^{1}(1-x)^n.e^x.dx$$

ក-ចូរគណនាតួ $I_1$ ។

ខ-ចូរបញ្ជាក់ $I_{n+1}$ ជាអនុគមន៍នៃ $I_n$ រួចទាញឱ្យបានថា :

$$I_n=e-\sum_{p=0}^{n}\left(\frac{1}{P!}\right)$$ ។

គ-ចូររកលីមីត $\lim\limits_{n\to+\infty} I_n$

រួចទាញថា $\lim\limits_{n\to+\infty}\left(1+\frac{1}{1!}+\frac{1}{2!}+\frac{1}{3!}+....+\frac{1}{n!}\right)=e=2.71828$

37. គេឱ្យ $f$ ជាអនុគមន៍គូលើ $[-a,a]$ ។

ក. ចូរបង្ហាញថា $\int_{-a}^{a}\frac{f(x).dx}{1+q^x}=\int_{0}^{a}f(x).dx$ , $q>0$ ,$q\ne 1$ ។

ខ. អនុវត្តន៍ :

ចូរគណនា $I=\int_{-\frac{\pi}{2}}^{\frac{\pi}{2}}\frac{\cos x}{1+3^x}.dx$ និង $J=\int_{-3}^{3}\frac{x^2-4|x|+3}{e^x+1}.dx$

38. ចូរបង្ហាញថា $\int_a^b f(x).dx=\int_a^b f(a+b-x).dx$

អនុវត្តន៏ :

ចូរគណនា $I=\int_0^{\frac{\pi}{3}}\log_2(1+\sqrt{3}\tan x).dx$

39. គេសន្មតថា f ជាអនុគមន៏មួយកំនត់លើ IR ហើយផ្ទៀងផ្ទាត់ទំនាក់ទំនង:

$f(x)+f(-x)=\sqrt{2-2\cos 2x}$ ។ ចូរគណនា $I=\int_{-\frac{\pi}{3}}^{\frac{\pi}{3}}f(x).dx$ ។

40. គេឱ្យស្វ៊ីតអាំងតេក្រាល $I_n=\int_0^{\frac{\pi}{2}}\sin^n x\cos^3 x.dx$ ដែល $n\in IN$ ។

ក. ចូរគណនា $I_n$ ជាអនុគមន៏នៃ n ។

ខ. ចូរគណនាផលបូក $S_n=\sum_{k=0}^{n}(I_k)=I_0+I_1+I_2+.........+I_n$

ជាអនុគមន៏នៃ n រួចទាញរកតម្លៃនៃលីមីត $\lim_{n\to+\infty}S_n$ ។

41. គេឱ្យស្វ៊ីតអាំងតេក្រាល $I_n = \int_0^1 x^n \sqrt{1-x^2}\,.dx$ ដែល $n \in IN$ ។

ក. ចូររកទំនាក់ទំនងរវាង $I_n$ និង $I_{n-2}$

ខ. គណនាផលគុណ $P_n = I_n . I_{n-1}$ , $\forall n \geq 1$ ជាអនុគមន៏នៃ $n$ ។

គ. ចូរគណនាផលបូក $S_n = \sum_{k=1}^{n} (P_k) = P_1 + P_2 + ........ + P_n$

ជាអនុគមន៏នៃ $n$ រួចទាញរកតម្លៃនៃលីមីត $\lim_{n \to +\infty} S_n$ ។

រករូបមន្តគណនា $I_n$ ជាអនុគមន៏នៃ $n$ ។

42. គេឱ្យអាំងតេក្រាល

$$I_n = \int_0^{\frac{\pi}{2}} \frac{\sqrt[n]{\sin^2 x}}{\sqrt[n]{\sin^2 x} + \sqrt[n]{\cos^2 x}}.dx$$

និង $$J_n = \int_0^{\frac{\pi}{2}} \frac{\sqrt[n]{\cos^2 x}}{\sqrt[n]{\sin^2 x} + \sqrt[n]{\cos^2 x}}.dx$$

ចូរបង្ហាញថា $I_n = J_n$ រួចទាញរកតម្លៃ $I_n$ និង $J_n$ ។

43. គេអោយអាំងតេក្រាល $I_n = \frac{1}{2n-1} . \int_0^1 \left(x^2\right)^n .dx$ , $n \in IN^*$ ។

ក-គណនា $I_n$ ជាអនុគមន៏នៃ $n$ ។

ខ-គណនាផលបូក $S_n = I_1 + I_2 + ... + I_n$ រកលីមីត $\lim_{n \to +\infty} S_n$ ។

44. គេអោយអាំងតេក្រាល $I_n = \int_{na}^{(n+1)a} \frac{dx}{\cos^2 x}$

និង $J_n = \int_{a}^{(n+1)a} \frac{dx}{\cos^2 x}$ $, n \in IN^*, a > 0$ ។

ក-បង្ហាញថា $I_1 + I_2 + I_3 + .... + I_n = J_n$ ។

ខ-គណនា $I_n$ និង $J_n$ ជាអនុគមន៍នៃ $n$ ។

គ-ប្រើលទ្ធផលខាងលើចូរបង្រួមផលបូក :

$$S_n = \frac{1}{\cos a \cos 2a} + \frac{1}{\cos 2a \cos 3a} + ......... + \frac{1}{\cos(na)\cos(n+1)a}$$ ។

45. គេឱ្យត្រីកោណ ABC មួយមានមុំ A,B,C ជាមុំស្រួច ។

ចូរស្រាយថា $\frac{\sin^2 A}{\cos^3 A} + \frac{\sin^2 B}{\cos^3 B} + \frac{\sin^2 C}{\cos^3 C} \geq 18$

46. គេឧបមាថាសមីការ $8x^3 - 6x + 1 = 0$ មានឫសបី $x_1, x_2, x_3$

ចូរគណនា $S = x_1^5 + x_2^5 + x_3^5$ ។

# ផ្នែកដំណោះស្រាយ

# គណិតវិទ្យាជុំវិញពិភពលោក

# ភាគទី ៨

រក្សាសិទ្ធិដោយ លឹម ផល្គុន

Tel : 017 768 246

## លំហាត់ទី១

ចូរកំណត់គ្រប់អនុគមន៍ $f: IR \to IR$ ដោយដឹងថាសមភាព

$f(\lfloor x \rfloor y) = f(x)\lfloor f(y) \rfloor$ ពិតជានិច្ចគ្រប់ $x, y \in IR$ ។

( $\lfloor a \rfloor$ តាងឱ្យផ្នែកគត់នៃ $a$ ) ។ ( IMO 2010 )

## ដំណោះស្រាយ

កំណត់គ្រប់អនុគមន៍ $f: IR \to IR$

គ្រប់ $x, y \in IR$ គេមានសមភាព

យក $x = 0$ និង $y = 0$ គេបាន $f(0) = f(0)\lfloor f(0) \rfloor$

គេទាញ $f(0)(1 - \lfloor f(0) \rfloor) = 0$ នោះ $f(0) = 0$ ឬ $\lfloor f(0) \rfloor = 1$

-ករណី $\lfloor f(0) \rfloor = 1$

យក $y = 0$ ជំនួសក្នុង (*) គេបាន $f(0) = f(x)\lfloor f(0) \rfloor$

ឬ $f(x) = f(0)$ នាំឱ្យ $f(x)$ ជាអនុគមន៍ថេរ

តាង $f(x) = c$ ជំនួសក្នុងសមីការ (*) គេបាន $c = c\lfloor c \rfloor$

នោះ $c = 0$ , $\lfloor c \rfloor = 1$ ។

ដូចនេះ $f(x) = 0$ ឬ $f(x) = c$ ដែល $c \in [1,2)$ ( ព្រោះ $\lfloor c \rfloor = 1$ )

-ករណី $f(0)=0$

យក $x=y=1$ ជំនួសក្នុង (*) គេបាន $f(1)=f(1)\lfloor f(1)\rfloor$

នោះ $f(1)=0$ ឬ $\lfloor f(1)\rfloor=1$

ក. ចំពោះ $f(1)=0$ នោះយើងយក $x=1$ ជំនួសក្នុង (*) គេបាន

$f(y)=f(1)\lfloor f(y)\rfloor=0\ \forall y\in IR$ ។

ខ. ចំពោះ $\lfloor f(1)\rfloor=1$ នោះយើងយក $y=1$ គេបាន $f(\lfloor x\rfloor)=f(x)$ (**)

យក $x=2$ , $y=\frac{1}{2}$ ក្នុង (*) គេបាន $f(1)=f(2)\left\lfloor f(\frac{1}{2})\right\rfloor$

តែតាម (**) គេបាន $f(\frac{1}{2})=f(0)=0$ ហេតុនេះគេទាញបាន $f(1)=0$

មិនពិតព្រោះ $\lfloor f(1)\rfloor=1$ ។

សរុបមកគេបានចម្លើយ $f(x)=0\ ,\forall x\in IR$

ឬ $f(x)=c\ ,\forall x\in IR$ ដែល $1\le c<2$ ។

## លំហាត់ទី២

ចំពោះគ្រប់ចំនួនពិត $x \in (0, \frac{\pi}{2})$

ចូរស្រាយថា $\frac{\sqrt{3}}{\sin x} + \frac{1}{\cos x} \geq 2 + \sqrt{3}$ ។

## ដំណោះស្រាយ

ស្រាយថា $\frac{\sqrt{3}}{\sin x} + \frac{1}{\cos x} \geq 2 + \sqrt{3}$

តាមវិសមភាព $Cauchy - Schwarz$ គេបាន :

$$\frac{\sqrt{3}}{\sin x} + \frac{1}{\cos x} = \frac{(\sqrt{3})^2}{\sqrt{3}\sin x} + \frac{1^2}{\cos x} \geq \frac{(\sqrt{3}+1)^2}{\sqrt{3}\sin x + \cos x}$$

ដោយ $\sqrt{3}\sin x + \cos x = 2\sin(x + \frac{\pi}{6}) \leq 2$

គេបាន $\frac{\sqrt{3}}{\sin x} + \frac{1}{\cos x} \geq \frac{(\sqrt{3}+1)^2}{2} = 2 + \sqrt{3}$

ដូចនេះ $\frac{\sqrt{3}}{\sin x} + \frac{1}{\cos x} \geq 2 + \sqrt{3}$ ។

## លំហាត់ទី៣

ដោះស្រាយសមីការ :

$$6+\log_{\frac{1}{3}}(1+2^x)+\log_3{}^2(1+2^x)=2\sqrt{8+\log_3{}^3(1+2^x)}$$

## ដំណោះស្រាយ

ដោះស្រាយសមីការ :

តាង $t=\log_3(1+2^x)$ សមីការអាចសរសេរ :

$$6-t+t^2=2\sqrt{8+t^3}$$

$$t^2-t+6=2\sqrt{(t+2)(t^2-2t+4)}$$

យក $u=t+2$ និង $v=t^2-2t+4$ ដែល $t\geq -2$

គេបាន $u+v=2\sqrt{uv}$

លើកជាការេ $u^2+2uv+v^2=4uv \Leftrightarrow (u-v)^2=0$

គេទាញ $u=v$ ឬ $t+2=t^2-2t+4$

$$t^2-3t+2=0 \Rightarrow t_1=1\ ,\ t_2=2$$

-ចំពោះ $t=1$ គេបាន $\log_3(1+2^x)=1$ នាំឱ្យ $x=1$ ។

-ចំពោះ $t=2$ គេបាន $\log_3(1+2^x)=2$ នាំឱ្យ $x=3$ ។

ដូចនេះ $x=1\ ;\ x=3$ ។

## លំហាត់ទី៤

គេមានអនុគមន៍ $f(x)=\dfrac{x+4}{x+1}$ ដែល $x\neq -1$ ។

គណនា $f_n[f[...f[f(x)]...]]$

## ដំណោះស្រាយ

គណនា $f_n[f[...f[f(x)]...]]$

តាង $a_1 = f(x)$

$$a_2 = f[f(x)] = f(a_1)$$

$$a_3 = f[f[f(x)]] = f(a_2)$$

$$-----------------$$

$$-----------------$$

$$a_n = f_n[f[....f[f(x)]....]] = f(a_{n-1})$$

គេបាន $a_{n+1} = f(a_n) = \dfrac{a_n+4}{a_n+1}$

ដូចនេះការគណនា $f_n[f[...f[f(x)]...]]$ គឺត្រូវកំណត់តួ $a_n$

នៃស្វ៊ីតដែលកំណត់ដោយ $\begin{cases} a_1 = f(x) = \dfrac{x+4}{x+1} \\ a_{n+1} = \dfrac{a_n+4}{a_n+1}, n\geq 1 \end{cases}$

សមីការសម្គាល់នៃស៊ីតគឺ $r = \dfrac{r+4}{r+1}$

គេបាន $r^2 + r = r + 4$ នាំឱ្យ $r_1 = -2$ , $r_2 = 2$

តាងស៊ីតជំនួយ $b_n = \dfrac{a_n - r_1}{a_n - r_2} = \dfrac{a_n + 2}{a_n - 2}$

គេបាន $b_{n+1} = \dfrac{a_{n+1} + 2}{a_{n+1} - 2} = \dfrac{\dfrac{a_n + 4}{a_n + 1} + 2}{\dfrac{a_n + 4}{a_n + 1} - 2}$

$$b_{n+1} = \frac{3a_n + 6}{-a_n + 2} = -3.\frac{a_n + 2}{a_n - 2} = -3b_n$$

នាំឱ្យ $(b_n)$ ជាស៊ីតធរណីមាត្រមានរេសុង $q = -3$

និងតួ $b_1 = \dfrac{a_1 + 2}{a_1 - 2} = \dfrac{x + 4 + 2x + 2}{x + 4 - 2x - 2} = -3.\dfrac{x+2}{x-2}$

តាមរូបមន្ត $b_n = b_1 \times q^{n-1} = \dfrac{x+2}{x-2} \times (-3)^n$

ដោយ $b_n = \dfrac{a_n + 2}{a_n - 2}$ គេទាញ $a_n = \dfrac{2(b+1)}{b-1}$

ដូចនេះ $a_n = \dfrac{2[(x+2)(-3)^n + x - 2]}{(x+2)(-3)^n - x + 2}$ ។

## លំហាត់ទី៥

គេឱ្យអនុគមន៍ $f(x)=\dfrac{1}{a+b\sin^2 x}+\dfrac{1}{c+b\cos^2 x}$

ដែល $a>0\ ,\ b>0$ ។

ចូរបង្ហាញថា $f(x)\geq\dfrac{4}{a+b+c}$ ចំពោះគ្រប់ចំនួនពិត $x$ ។

## ដំណោះស្រាយ

បង្ហាញថា $f(x)\geq\dfrac{4}{a+b+c}$

តាមវិសមភាព $(a_1b_1+a_2b_2)^2\leq(a_1{}^2+a_2{}^2)(b_1{}^2+b_2{}^2)$

យក $a_1=\sqrt{a+b\sin^2 x}\ ,\ a_2=\sqrt{c+b\cos^2 x}$

និង $b_1=\dfrac{1}{\sqrt{a+b\sin^2 x}}\ ,\ b_2=\dfrac{1}{\sqrt{c+b\cos^2 x}}$

គេបាន $(1+1)^2\leq(a+b\sin^2 x+c+b\cos^2 x).f(x)$

គេទាញបាន $f(x)\geq\dfrac{4}{a+c+b(\sin^2 x+\cos^2 x)}$

ដោយ $\sin^2 x+\cos^2 x=1$ គ្រប់ចំនួនពិត $x$

ដូចនេះ $f(x)\geq\dfrac{4}{a+b+c}$ ។

## លំហាត់ទី៦

គេមានស្វ៊ីត $(x_n)$ និង $(y_n)$ កំណត់ដោយ $\begin{cases} x_0 = 1 \\ y_0 = 0 \end{cases}$ និង

$$\begin{cases} x_{n+1} = \frac{1}{2}(\sin a + \cos a)x_n + \frac{1}{2}\sin a(1-\tan a)y_n \\ y_{n+1} = \frac{1}{2}\cos a(\cot a - 1)x_n + \frac{1}{2}(\sin a + \cos a)y_n \end{cases}$$

ដែល $0 < a < \frac{\pi}{2}$ និង $n = 0,1,2,....$ ។

ក. ចំពោះគ្រប់ $n \geq 0$ តាង $u_n = x_n \cos a + y_n \sin a$ និង

$v_n = x_n \cos a - y_n \sin a$ ។

ចូរស្រាយថា $(u_n)$ និង $(v_n)$ សុទ្ធតែជាស្វ៊ីតធរណីមាត្រ ។

ខ.គណនា $u_n$ និង $v_n$ ជាអនុគមន៍នៃ $n$ និង $a$ ។

គ. ទាញរក $x_n$ និង $y_n$ ជាអនុគមន៍នៃ $n$ និង $a$ ។

## ដំណោះស្រាយ

ក. ស្រាយថា $(u_n)$ និង $(v_n)$ សុទ្ធតែជាស្វ៊ីតធរណីមាត្រ

គេមាន :

$$x_{n+1} = \frac{1}{2}(\sin a + \cos a)x_n + \frac{1}{2}\sin a(1-\tan a)y_n$$

គុណអង្គទាំងពីរនឹង $\cos a$ គេបាន :

$$x_{n+1}\cos a = \frac{\cos a(\sin a + \cos a)}{2}x_n + \frac{\sin a(\cos a - \sin a)}{2}y_n \quad (1)$$

គេមាន :

$$y_{n+1} = \frac{1}{2}\cos a(\cot a - 1)x_n + \frac{1}{2}(\sin a + \cos a)y_n$$

គុណអង្គទាំងពីរនឹង $\sin a$ គេបាន :

$$y_{n+1}\sin a = \frac{\cos a(\cos a - \sin a)}{2}x_n + \frac{\sin a(\sin a + \cos a)}{2}y_n \quad (2)$$

បូកសមីការ **(1)** និង **(2)** អង្គ និង អង្គគេបាន :

$$x_{n+1}\cos a + y_{n+1}\sin a = \cos a(x_n\cos a + y_n\sin a)$$

ដោយ $u_n = x_n\cos a + y_n\sin a$

គេទាញបាន $u_{n+1} = \cos a . u_n$ នាំឱ្យ $(u_n)$ ជាស្វ៊ីតធរណីមាត្រមាន

រេសុង $q_u = \cos a$ ។

ដកសមីការ **(1)** និង **(2)** អង្គ និង អង្គគេបាន :

$$x_{n+1}\cos a - y_{n+1}\sin a = \sin a(x_n\cos a - y_n\sin a)$$

ដោយ $v_n = x_n\cos a - y_n\sin a$

គេទាញបាន $v_{n+1} = \sin a . v_n$ នាំឱ្យ $(v_n)$ ជាស្វ៊ីតធរណីមាត្រមាន

រេសុង $q_v = \sin a$ ។

ខ.គណនា $u_n$ និង $v_n$ ជាអនុគមន៍នៃ $n$ និង $a$

គេមាន $u_0 = x_0 \cos a + y_0 \sin a = \cos a$

គេបាន $u_n = u_0 \times {q_u}^n = \cos a . \cos^n a = \cos^{n+1} a$

ហើយ $v_0 = x_0 \cos a - y_0 \sin a = \cos a$

គេបាន $v_n = v_0 \times {q_v}^n = \cos a . \sin^n a$

ដូចនេះ $u_n = \cos^{n+1} a$ , $v_n = \cos a \sin^n a$ ។

គ. ទាញរក $x_n$ និង $y_n$ ជាអនុគមន៍នៃ $n$ និង $a$

ដោយ $u_n = x_n \cos a + y_n \sin a$

និង $v_n = x_n \cos a - y_n \sin a$

គេបាន $u_n + v_n = 2x_n \cos a$

គេទាញ $x_n = \dfrac{\cos^{n+1} a + \cos a \sin^n a}{2\cos a}$

$$x_n = \frac{\cos^n a + \sin^n a}{2}$$ ។

ហើយ $u_n - v_n = 2y_n \sin a$

គេទាញ $y_n = \dfrac{\cos^{n+1} a - \cos a \sin^n a}{2\sin a}$ ។

## លំហាត់ទី៧

គេឱ្យអនុគមន៍ $f$ កំណត់គ្រប់ $x \in IR$ ដោយទំនាក់ទំនង :

$$f(x)+\sqrt{2}f(\frac{\pi}{4}-x)=\sin x+3\cos x$$

ចូរស្រាយថា $|f(x)| \leq \sqrt{2}$ គ្រប់ $x \in IR$ ។

## ដំណោះស្រាយ

ស្រាយថា $|f(x)| \leq \sqrt{2}$

គេមាន $f(x)+\sqrt{2}f(\frac{\pi}{4}-x)=\sin x+3\cos x \quad (1)$

ជំនួស $x$ ដោយ $\frac{\pi}{4}-x$ ក្នុង $(1)$ គេបាន :

$$f(\frac{\pi}{4}-x)+\sqrt{2}f(x)=\sin(\frac{\pi}{4}-x)+3\cos(\frac{\pi}{4}-x)$$

$$f(\frac{\pi}{4}-x)+\sqrt{2}f(x)=\sqrt{2}\sin x+2\sqrt{2}\cos x$$

$$\sqrt{2}f(\frac{\pi}{4}-x)+2f(x)=2\sin x+4\cos x \quad (2)$$

ដកសមីការ $(2)$ និង $(1)$ អង្គ និងអង្គគេបាន $f(x)=\sin x+\cos x$

ហេតុនេះ $|f(x)| \leq \sqrt{1^2+1^2}.\sqrt{\sin^2 x+\cos^2 x}=\sqrt{2}$

ដូចនេះ $|f(x)| \leq \sqrt{2}$ គ្រប់ $x \in IR$ ។

## លំហាត់ទី៨

គេឱ្យអនុគមន៍ $f$ កំណត់គ្រប់ $x \in IR$ ដោយទំនាក់ទំនង :

$$2f(\frac{\pi}{2}-x)+f(\frac{\pi}{2}+x)=\sin x+3\sqrt{3}\cos x$$

កំណត់ចំនួនពិត $r$ និង $\varphi$ ដើម្បីឱ្យអនុគមន៍ $f(x)$ អាចសរសេរ :

$f(x)=r\sin(x+\varphi)$ គ្រប់ $x \in IR$ ។

## ដំណោះស្រាយ

កំណត់ចំនួនពិត $r$ និង $\varphi$

គេមាន $2f(\frac{\pi}{2}-x)+f(\frac{\pi}{2}+x)=\sin x+3\sqrt{3}\cos x$ (1)

ជំនួស $x$ ដោយ $-x$ គេបាន :

$$2f(\frac{\pi}{2}+x)+f(\frac{\pi}{2}-x)=-\sin x+3\sqrt{3}\cos x$$

$$4f(\frac{\pi}{2}+x)+2f(\frac{\pi}{2}-x)=-2\sin x+6\sqrt{3}\cos x \quad (2)$$

ដកសមីការ (2) និង (1) អង្គ និងអង្គគេបាន

$$3f(\frac{\pi}{2}+x)=-3\sin x+3\sqrt{3}\cos x$$

ឬ $f(\frac{\pi}{2}+x)=-\sin x+\sqrt{3}\cos x$ (3)

ជំនួស $x$ ដោយ $-\frac{\pi}{2}+x$ គេបាន :

$$f(x)=-\sin(-\frac{\pi}{2}+x)+\sqrt{3}\cos(-\frac{\pi}{2}+x)$$

$$f(x)=\cos x+\sqrt{3}\sin x$$

$$f(x)=2(\frac{1}{2}\cos x+\frac{\sqrt{3}}{2}\sin x)$$

$$f(x)=2(\sin x\cos\frac{\pi}{6}+\sin\frac{\pi}{6}\cos x)$$

$$f(x)=2\sin(x+\frac{\pi}{6})$$

ដោយប្រៀបធៀបជាមួយនឹង $f(x)=r\sin(x+\varphi)$

ដូចនេះ $r=2$ ; $\varphi=\frac{\pi}{6}$ ។

## លំហាត់ទី៩

គេឱ្យអនុគមន៍ $f$ កំណត់គ្រប់ $x \in IR$ ដោយទំនាក់ទំនង :

$$5f(x) - 3\sin x\ f(\pi - x) = 4\cos x$$

ចូររកតម្លៃតូចបំផុត និង ធំបំផុតនៃ $f(x)$

## ដំណោះស្រាយ

រកតម្លៃតូចបំផុត និង ធំបំផុតនៃ $f(x)$

$$5f(x) - 3\sin x\ f(\pi - x) = 4\cos x \quad (1)$$

ជំនួស $x$ ដោយ $\pi - x$ ក្នុង (1) គេបាន :

$$5f(\pi - x) - 3\sin(\pi - x).f(x) = 4\cos(\pi - x)$$

$$5f(\pi - x) - 3\sin x.f(x) = -4\cos x$$

$$f(\pi - x) - \frac{3\sin x}{5}.f(x) = -\frac{4\cos x}{5}$$

$$3\sin x.f(\pi - x) - \frac{9\sin^2 x}{5}f(x) = -\frac{12\sin x\cos x}{5} \quad (2)$$

បូកសមីការ (1) និង (2) គេបាន :

$$\left(5 - \frac{9\sin^2 x}{5}\right)f(x) = \frac{4\cos x(5 - 3\sin x)}{5}$$

$$f(x) = \frac{4\cos x(5 - 3\sin x)}{(25 - 9\sin^2 x)}$$

$$f(x)=\frac{4\cos x(5-3\sin x)}{(5+3\sin x)(5-3\sin x)}$$

$$f(x)=\frac{4\cos x}{5+3\sin x}$$

$$(5+3\sin x)f(x)=4\cos x$$

$$5f(x)+3f(x)\sin x=4\cos x$$

$$4\cos x-3f(x)\sin x=5f(x)\quad(1)$$

តាមវិសមភាព $Cauchy-Schwarz$ គេបាន :

$$|4\cos x-3f(x)\sin x|\le\sqrt{16+9f^2(x)}\quad(2)$$

តាម (1) និង (2) គេបាន :

$$|5f(x)|\le\sqrt{16+9f^2(x)}$$

$$25f^2(x)\le16+9f^2(x)$$

$$f^2(x)\le1$$

$$|f(x)|\le1\Leftrightarrow-1\le f(x)\le1$$

ដូចនេះ $f_{\min}(x)=-1$ និង $f_{\max}(x)=1$ ។

## លំហាត់ទី១០

គេឱ្យអនុគមន៍ $f$ និង $g$ កំណត់គ្រប់ $x \in IR$ ដោយទំនាក់ទំនង :

$$\begin{cases} f(x)+g(\frac{\pi}{2}-x)=2\sin x \\ 3f(\frac{\pi}{2}-x)-g(x)=2\cos x \end{cases}$$

ចូររកអនុគមន៍ $f(x)$ និង $g(x)$

## ដំណោះស្រាយ

រកអនុគមន៍ $f(x)$ និង $g(x)$

គេមាន $\begin{cases} f(x)+g(\frac{\pi}{2}-x)=2\sin x & (1) \\ 3f(\frac{\pi}{2}-x)-g(x)=2\cos x & (2) \end{cases}$

ជំនួស $x$ ដោយ $\frac{\pi}{2}-x$ ក្នុង $(2)$ គេបាន :

$$3f(x)-g(\frac{\pi}{2}-x)=2\cos(\frac{\pi}{2}-x)$$

$$3f(x)-g(\frac{\pi}{2}-x)=2\sin x \quad (3)$$

បូកសមីការ $(1)\,\&\,(3)$ គេបាន $4f(x)=4\sin x$

គេទាញ $f(x) = \sin x$ ។

តាម (1) គេទាញបាន $g(\frac{\pi}{2} - x) = 2\sin x - f(x) = \sin x$

ជំនួស $x$ ដោយ $\frac{\pi}{2} - x$ គេបាន $g(x) = \sin(\frac{\pi}{2} - x) = \cos x$

ដូចនេះ $f(x) = \sin x$ ; $g(x) = \cos x$ ។

## លំហាត់ទី១១

គេឱ្យអនុគមន៍ $f$ កំណត់គ្រប់ $x \in (-1,1)$ ដោយទំនាក់ទំនង :

$$f(x) - 2f(-x) = \ln(\frac{1-3x+3x^2-x^3}{1+3x+3x^2+x^3})$$

ចូររក $f(\cos\theta)$ ជាអនុគមន៍នៃ $t = \tan\frac{\theta}{2}$ ដែល $-\frac{\pi}{2} < \theta < \frac{\pi}{2}$

## ដំណោះស្រាយ

រក $f(\cos\theta)$ ជាអនុគមន៍នៃ $t = \tan\frac{\theta}{2}$

គេមាន $f(x) - 2f(-x) = \ln(\frac{1-3x+3x^2-x^3}{1+3x+3x^2+x^3})$

$$f(x) - 2f(-x) = \ln\left(\frac{1-x}{1+x}\right)^3$$

$$f(x) - 2f(-x) = 3\ln(\frac{1-x}{1+x}) \quad (1)$$

ជំនួស $x$ ដោយ $-x$ ក្នុង $(1)$ គេបាន :

$$f(-x) - 2f(x) = 3\ln(\frac{1+x}{1-x})$$

$$2f(-x) - 4f(x) = -6\ln(\frac{1-x}{1+x}) \quad (2)$$

បូកសមីការ **(1)** និង **(2)** គេបាន :

$$-3f(x) = -3\ln(\frac{1-x}{1+x})$$

$$f(x) = \ln(\frac{1-x}{1+x})$$

ហេតុនេះ $f(\cos\theta) = \ln(\frac{1-\cos\theta}{1+\cos\theta})$

$$= \ln(\frac{2\sin^2\frac{\theta}{2}}{2\cos^2\frac{\theta}{2}})$$

$$= \ln(\tan^2\frac{\theta}{2})$$

$$= 2\ln|\tan\frac{\theta}{2}|$$

ដោយ $t = \tan\frac{\theta}{2}$ ដូចនេះ $f(\cos\theta) = \ln|t|$ ។

## លំហាត់ទី១២

គេឱ្យអនុគមន៍ $f$ កំណត់គ្រប់ $x \in IR$ ដោយទំនាក់ទំនង :

$$f(x)+3f(-x)+8=4(e^{\frac{x}{2}}+e^{-\frac{x}{2}})^2$$

ចូរគណនាលីមីត $\lim_{x\to 0}\frac{f(x)-2}{x^2}$

## ដំណោះស្រាយ

គណនាលីមីត $\lim_{x\to 0}\frac{f(x)-2}{x^2}$

គេមាន $\mathbf{f(x)+3f(-x)+8=4(e^{\frac{x}{2}}+e^{-\frac{x}{2}})^2}$ **(1)**

ជំនួស $\mathbf{x}$ ដោយ $\mathbf{-x}$ ក្នុងទំនាក់ទំនង **(1)** គេបាន :

$$\mathbf{f(-x)+3f(x)+8=4(e^{-\frac{x}{2}}+e^{\frac{x}{2}})^2}$$

$$\mathbf{3f(-x)+9f(x)+24=12(e^{\frac{x}{2}}+e^{-\frac{x}{2}})^2} \quad \mathbf{(2)}$$

ធ្វើផលដកសមីការ **(2) & (1)** គេបាន :

$$\mathbf{8f(x)+16=8(e^{\frac{x}{2}}+e^{-\frac{x}{2}})^2}$$

$$\mathbf{\Rightarrow f(x)=e^{x}+e^{-x}}$$

យើងបាន $\lim_{x\to 0}\frac{f(x)-2}{x^2}=\lim_{x\to 0}\frac{e^x+e^{-x}-2}{x^2}$

$$=\lim_{x\to 0}\frac{e^x+\frac{1}{e^x}-2}{x^2}$$

$$=\lim_{x\to 0}\frac{e^{2x}-2e^x+1}{x^2e^x}$$

$$=\lim_{x\to 0}\left(\frac{e^x-1}{x}\right)^2.\frac{1}{e^x}=1$$

ដូចនេះ $\lim_{x\to 0}\frac{f(x)-2}{x^2}=1$ ។

## លំហាត់ទី១៣

គេឱ្យអនុគមន៍ $\mathbf{f : IR \mapsto IR}$ កំណត់ដោយទំនាក់ទំនង :

$$\begin{cases} f(1) = -2 \\ (x-y)f(x+y) - (x+y)f(x-y) = 4xy(x^2 - y^2) \end{cases}$$

ក. កំណត់រកអនុគមន៍ $\mathbf{f(x)}$

ខ. កំណត់ $\mathbf{x}$ ដើម្បីឱ្យ $\mathbf{f(x) = \sqrt{3}}$ ។

## ដំណោះស្រាយ

ក. កំណត់រកអនុគមន៍ $\mathbf{f(x)}$

$$(x-y)f(x+y) - (x+y)f(x-y) = 4xy(x^2 - y^2) \quad (1)$$

យក $\mathbf{x = 1 , y = 1}$ ជំនួសក្នុង $\mathbf{(1)}$ គេបាន :

$\mathbf{-2f(0) = 0}$ នាំឱ្យ $\mathbf{f(0) = 0}$

តាង $\mathbf{x + y = u}$ និង $\mathbf{x - y = v}$ នោះ $\begin{cases} x = \dfrac{u+v}{2} \\ y = \dfrac{u-v}{2} \end{cases}$

ទំនាក់ទំនង $\mathbf{(1)}$ អាចសរសេរ :

$$uf(v) - vf(u) = uv(u^2 - v^2)$$

ចែកសមីការនេះនឹង $\mathbf{uv \neq 0}$ គេបាន :

$$\frac{f(v)}{v}-\frac{f(u)}{u}=u^2-v^2$$

$$\frac{f(u)}{u}-u^2=\frac{f(v)}{v}-v^2$$

តាមទំនាក់ទំនងនេះបញ្ជាក់ថា $\frac{f(x)}{x}-x^2$ ជាអនុគមន៍ថេរគ្រប់ $x\neq 0$

គេទាញ $\frac{f(x)}{x}-x^2=\frac{f(1)}{1}-1^2=-3$

ដូចនេះ $f(x)=x(x^2-3)$ ។

ខ. កំណត់ $x$ ដើម្បីឱ្យ $f(x)=\sqrt{3}$

គេបាន $x(x^2-3)=\sqrt{3}$

$x^3-3x=\sqrt{3}$ តាង $x=2\cos\varphi$ គេបាន

$8\cos^3\varphi-6\cos\varphi=\sqrt{3}$

$2\cos 3\varphi=\sqrt{3}$

$$3\varphi=\frac{\pi}{6}+2k\pi \quad ,k=0,1,2$$

គេទាញ $\varphi\in\{\frac{\pi}{18},\frac{13\pi}{18},\frac{25\pi}{18}\}$

ដូចនេះ $x_1=2\cos\frac{\pi}{18}, x_2=2\cos\frac{13\pi}{18}, x_3=2\cos\frac{25\pi}{18}$

## លំហាត់ទី១៤

ចំពោះ $a$ និង $b$ ជាចំនួនពិត សមីការ

$x^4+ax^3+bx^2+ax+1=0$ មានឬសយ៉ាងតិច

មួយជាចំនួនពិត ។

ចូរគណនាតម្លៃតូចបំផុតនៃ $a^2+b^2$ ? **(IMO 1973)**

## ដំណោះស្រាយ

គណនាតម្លៃតូចបំផុតនៃ $a^2+b^2$

គេមាន $x^4+ax^3+bx^2+ax+1=0$

ចែកអង្គទាំងពីរនៃសមីការនេះ នឹង $x^2\neq 0$ គេបាន :

$$x^2+ax+b+\frac{a}{x}+\frac{1}{x^2}=0$$

$$x^2+\frac{1}{x^2}+a(x+\frac{1}{x})+b=0$$

$$(x+\frac{1}{x})^2+a(x+\frac{1}{x})+b-2=0$$

តាង $z=x+\frac{1}{x}$ សមីការនេះអាចសរសេរ :

$z^2+az+b-2=0$ ឬ $az+b=2-z^2$ (1)

តាមវិសមភាព **Cauchy – Schwarz** គេមាន :

$$(az+b)^2 \le (a^2+b^2)(z^2+1) \quad (2)$$

តាម **(1) & (2)** គេបាន :

$$(a^2+b^2)(z^2+1) \ge (2-z^2)^2$$

$$a^2+b^2 \ge \frac{(2-z^2)^2}{z^2+1}$$

$$a^2+b^2 \ge \frac{[3-(1+z^2)]^2}{z^2+1}$$

$$a^2+b^2 \ge z^2-5+\frac{9}{z^2+1}$$

យក $t = z^2$ ដោយ $z = x+\frac{1}{x} = \frac{x^2+1}{x}$

នោះ $|z| \ge \frac{|x^2+1|}{|x|} \ge \frac{|2x|}{|x|} = 2$ ហើយ $t = z^2 = |z|^2 \ge 4$

គេបាន $a^2+b^2 \ge t-5+\frac{9}{t+1}$

តាងអនុគមន៍ $f(t) = t-5+\frac{9}{t+1}$

គេបាន $f'(t) = 1-\frac{9}{(t+1)^2} = \frac{(t+4)(t-2)}{(t+1)^2} > 0 \; \forall t \ge 4$

គេទាញបាន $\mathbf{f(t)}$ ជាអនុគមន៍កើនគ្រប់ $\mathbf{t \geq 4}$ ។

តាមលក្ខណៈនៃអនុគមន៍កើនគេបាន $\mathbf{f(t) \geq f(4)}$

តែ $\mathbf{f(4) = 4 - 5 + \frac{9}{4+1} = -1 + \frac{9}{5} = \frac{4}{5}}$ នោះ $\mathbf{f(t) \geq \frac{4}{5}}$

គេទាញបាន $\mathbf{a^2 + b^2 \geq f(t) \geq \frac{4}{5}}$

ដូចនេះ តម្លៃតូចបំផុតនៃ $\mathbf{a^2 + b^2}$ ស្មើនឹង $\mathbf{\frac{4}{5}}$ ។

## លំហាត់ទី១៥

គេឱ្យអនុគមន៍លេខ $\mathbf{f}$ កំនត់ដោយទំនាក់ទំនង :

$\mathbf{f(1)=\frac{7}{5}}$ និង $\mathbf{f(n+1)=\frac{13f(n)-16}{9f(n)-11}}$ ដែល $\mathbf{n=1,2,3,...}$

ចូរស្រាយថា $\mathbf{f(n)}$ ជាប្រភាគសម្រួលមិនបាន ។

## ដំណោះស្រាយ

ស្រាយថា $\mathbf{f(n)}$ ជាប្រភាគសម្រួលមិនបាន :

សមីការសម្គាល់ $\mathbf{r=\frac{13r-16}{9r-11}}$

$$\mathbf{9r^2-11r=13r-16}$$

$$\mathbf{9r^2-24r+16=0}$$

$$\mathbf{(3r-4)^2=0\Rightarrow r=\frac{4}{3}}$$

តាងស្វ៊ីតជំនួយ $\mathbf{z_n=\frac{1}{f(n)-\frac{4}{3}}}$

គេបាន $\mathbf{z_{n+1}=\frac{1}{f(n+1)-\frac{4}{3}}}$ ដោយ $\mathbf{f(n+1)=\frac{13f(n)-16}{9f(n)-11}}$

នោះ $z_{n+1} = \dfrac{1}{\dfrac{13f(n)-16}{9f(n)-11} - \dfrac{4}{3}}$

$= \dfrac{9f(n)-11}{\dfrac{39f(n)-48-36f(n)+44}{3}}$

$= \dfrac{9f(n)-11}{f(n)-\dfrac{4}{3}}$

គេមាន $z_{n+1} - z_n = \dfrac{9f(n)-11}{f(n)-\dfrac{4}{3}} - \dfrac{1}{f(n)-\dfrac{4}{3}} = 9$ ថេរ

នាំឱ្យ $(z_n)$ ជាស្វ៊ីតនព្វន្តមានផលសងរួម $d = 9$ និង $z_1 = \dfrac{1}{f(1)-\dfrac{4}{3}}$

តែ $f(1) = \dfrac{7}{5}$ នោះ $z_1 = \dfrac{1}{\dfrac{7}{5}-\dfrac{4}{3}} = 15$ ។

គេបាន $z_n = z_1 + (n-1)d = 15 + 9(n-1) = 9n+6$

ហើយ $z_n = \dfrac{1}{f(n)-\dfrac{4}{3}}$ នោះ $f(n) = \dfrac{1}{z_n} + \dfrac{4}{3}$

$$f(n) = \frac{1}{9n+6} + \frac{4}{3} = \frac{1+4(3n+2)}{3(3n+2)} = \frac{4n+3}{3n+2}$$

តាង $\mathbf{GCD(4n+3, 3n+2) = d}$

គេបាន $\begin{cases} 4n+3 = dp \\ 3n+2 = dq \end{cases}$ ដែល $\mathbf{GCD(p,q) = 1}$

គេមាន $\mathbf{3(4n+3) - 4(3n+2) = 3dp - 4dq}$

$$\mathbf{1 = (3p - 4q)d}$$

គេទាញបាន $\mathbf{1}$ ចែកដាច់នឹង $\mathbf{d}$ នោះ $\mathbf{d = 1}$

នាំឱ្យ$\mathbf{GCD(4n+3, 3n+2) = 1}$ ។

ដូចនេះ $\mathbf{f(n) = \frac{4n+3}{3n+2}}$ ជាប្រភាគសម្រួលមិនបាន ។

## លំហាត់ទី១៦

គេឱ្យស្វ៊ីតនៃចំនួនពិត $(u_n)$ កំណត់ដោយ :

$u_1 = \frac{7}{2}$ និង $u_{n+1} = u_n^2 + u_n - \frac{1}{4}$ គ្រប់ $n \geq 1$

បង្ហាញថាគេអាចកំណត់ចំនួនពិត $a$ ដែល $u_{n+1} + a = (u_n + a)^2$

ចំពោះគ្រប់ $n \geq 1$ រួចគណនា $u_n$ ជាអនុគមន៍នៃ $n$ ។

## ដំណោះស្រាយ

កំណត់ចំនួនពិត $a$

គេមាន $u_{n+1} = u_n^2 + u_n - \frac{1}{4}$ (1)

ហើយ $u_{n+1} + a = (u_n + a)^2$ (2)

យក (1) ជំនួសក្នុង (2) គេបាន :

$$u_n^2 + u_n - \frac{1}{4} + a = (u_n + a)^2$$

$$u_n^2 + u_n - \frac{1}{4} + a = u_n^2 + 2au_n + a^2$$

$$(1 - 2a)u_n = a^2 - a + \frac{1}{4}$$

សមីការនេះពិតជានិច្ចចំពោះគ្រប់តម្លៃ $n$ លុះត្រាតែ :

$$\begin{cases} 1-2a=0 \\ a^2-a+\frac{1}{4}=0 \end{cases}$$ នាំឱ្យ $a=\frac{1}{2}$

ដូចនេះ $a=\frac{1}{2}$ ។

គណនា $u_n$ ជាអនុគមន៍នៃ $n$ :

ចំពោះ $a=\frac{1}{2}$ គេបាន $u_{n+1}+\frac{1}{2}=(u_n+\frac{1}{2})^2$

គេទាញ $\ln(u_{n+1}+\frac{1}{2})=2\ln(u_n+\frac{1}{2})$ (3)

តាង $v_n=\ln(u_n+\frac{1}{2}) \Rightarrow v_{n+1}=\ln(u_{n+1}+\frac{1}{2})$

តាម (3) គេបាន $v_{n+1}=2v_n$ នាំឱ្យ $(v_n)$ ជាស្វ៊ីតធរណីមាត្រ

មានផលធៀបរួម $q=2$ និង $v_1=\ln(u_1+\frac{1}{2})=\ln 4$

គេបាន $v_n=v_1\times q^{n-1}=2^{n-1}\ln 4=2^n\ln 2=\ln 2^{2^n}$

ដោយ $v_n=\ln(u_n+\frac{1}{2})$ គេទាញ $u_n+\frac{1}{2}=2^{2^n}$

ដូចនេះ $v_n=2^{2^n}-\frac{1}{2}$ ។

## លំហាត់ទី១៧

គេឱ្យចំនួនកុំផ្លិច $z=\sqrt{2+\cos\varphi}+i\sqrt{2+\sin\varphi}$ ដែល $\varphi\in IR$

ក្នុងប្លង់កំផ្លិច $(o,\vec{i},\vec{j})$ គេហៅ $M$ ជាចំនុចរូបភាពនៃ $z$ ។

ចូរកំណត់តម្លៃតូចបំផុត និង ធំបំផុតនៃ $r=OM$ ?

## ដំណោះស្រាយ

កំណត់តម្លៃតូចបំផុត និង ធំបំផុតនៃ $r=OM$

គេមាន :

$$OM^2=a^2+b^2=(\sqrt{2+\cos\varphi})^2+(\sqrt{2+\sin\varphi})^2$$

$OM^2=4+\cos\varphi+\sin\varphi$ ឬ $OM=\sqrt{4+\cos\varphi+\sin\varphi}$

គេបាន $r=\sqrt{4+\cos\varphi+\sin\varphi}$

តាមវិសមភាព $Cauchy-Schwarz$ គេមាន :

$$|\cos\varphi+\sin\varphi|\le\sqrt{1^2+1^2}\sqrt{\cos^2\varphi+\sin^2\varphi}=\sqrt{2}$$

ឬ $-\sqrt{2}\le\cos\varphi+\sin\varphi\le\sqrt{2}$

គេទាញ $\sqrt{4-\sqrt{2}}\le r\le\sqrt{4+\sqrt{2}}$ គ្រប់ $\varphi\in IR$

ដូចនេះ $r_{min}=\sqrt{4-\sqrt{2}}$ និង $r_{max}=\sqrt{4+\sqrt{2}}$ ។

## លំហាត់ទី១៨

គេឱ្យចំនួនកុំផ្លិច $z_1, z_2, z_3$ ហើយផ្ទៀងផ្ទាត់ទំនាក់ទំនង :

$|z_1| = |z_2| = |z_3| = 1$ និង $\frac{z_1^2}{z_2 z_3} + \frac{z_2^2}{z_1 z_3} + \frac{z_3^2}{z_1 z_2} + 1 = 0$

ចូរស្រាយថា $|z_1 + z_2 + z_3| \in \{1, 2\}$ ។

## ដំណោះស្រាយ

ស្រាយថា $|z_1 + z_2 + z_3| \in \{1, 2\}$

គេមាន $\frac{z_1^2}{z_2 z_3} + \frac{z_2^2}{z_1 z_3} + \frac{z_3^2}{z_1 z_2} + 1 = 0$

គេបាន $z_1^3 + z_2^3 + z_3^3 + z_1 z_2 z_3 = 0$

ឬ $z_1^3 + z_2^3 + z_3^3 - 3z_1 z_2 z_3 = -4z_1 z_2 z_3$

តាង $z = z_1 + z_2 + z_3$ គេបាន :

$$z^3 - 3z(z_1 z_2 + z_2 z_3 + z_1 z_3) = -4z_1 z_2 z_3$$

$$z^3 = z_1 z_2 z_3 \left[ 3z\left(\frac{1}{z_1} + \frac{1}{z_2} + \frac{1}{z_3}\right) - 4 \right]$$

$$z^3 = z_1 z_2 z_3 \left[ 3z(\overline{z_1} + \overline{z_2} + \overline{z_3}) - 4 \right]$$

$$z^3 = z_1 z_2 z_3 (3z.\overline{z} - 4) = z_1 z_2 z_3 \left(3|z|^2 - 4\right)$$

គេបាន $|z|^3 = |z_1 z_2 z_3 (3|z|^2 - 4)|$

ឬ $|z|^3 = |3|z|^2 - 4|$

-បើ $3|z|^2 - 4 \geq 0$ ឬ $|z| \geq \frac{2}{\sqrt{3}}$

គេបាន $|z|^3 = 3|z|^2 - 4$

$$|z|^3 - 3|z|^2 + 4 = 0$$

$$(|z|+1)(|z|-2)^2 = 0 \Rightarrow |z| = 2$$

-បើ $3|z|^2 - 4 < 0$ ឬ $|z| < \frac{2}{\sqrt{3}}$

គេបាន $|z|^3 = -(3|z|^2 - 4)$

$$|z|^3 + 3|z|^2 - 4 = 0$$

$$(|z|-1)(|z|+2)^2 = 0 \Rightarrow |z| = 1$$

ដូចនេះ $|z_1 + z_2 + z_3| \in \{1, 2\}$ ។

## លំហាត់ទី១៩

គេឱ្យចំនួនកុំផ្លិច $\mathbf{z_1}$ និង $\mathbf{z_2}$ ដែល $|\mathbf{z_1}|=|\mathbf{z_2}|=\mathbf{1}$

ចូរស្រាយថា $|\mathbf{z_1}+\mathbf{1}|+|\mathbf{z_2}+\mathbf{1}|+|\mathbf{z_1 z_2}+\mathbf{1}|\geq \mathbf{2}$

## ដំណោះស្រាយ

ស្រាយថា $|\mathbf{z_1}+\mathbf{1}|+|\mathbf{z_2}+\mathbf{1}|+|\mathbf{z_1 z_2}+\mathbf{1}|\geq \mathbf{2}$

តាមវិសមភាពត្រីកោណ $|\mathbf{a}|+|\mathbf{b}|\geq|\mathbf{a}\pm\mathbf{b}|$ គេបាន :

$|\mathbf{z_2}+\mathbf{1}|+|\mathbf{z_1 z_2}+\mathbf{1}|\geq|\mathbf{z_2}+\mathbf{1}-\mathbf{z_1 z_2}-\mathbf{1}|$

$|\mathbf{z_2}+\mathbf{1}|+|\mathbf{z_1 z_2}+\mathbf{1}|\geq|\mathbf{z_2}||\mathbf{1}-\mathbf{z_1}|=|\mathbf{1}-\mathbf{z_1}|$

ហើយ $|\mathbf{z_1}+\mathbf{1}|+|\mathbf{1}-\mathbf{z_1}|\geq|(\mathbf{z_1}+\mathbf{1}+\mathbf{1}-\mathbf{z_1})|=\mathbf{2}$

ដូចនេះ $|\mathbf{z_1}+\mathbf{1}|+|\mathbf{z_2}+\mathbf{1}|+|\mathbf{z_1 z_2}+\mathbf{1}|\geq \mathbf{2}$ ។

## លំហាត់ទី២០

គេឱ្យស្វ៊ីតចំនួនពិត $(a_n)$ កំណត់ដោយ :

$$\begin{cases} a_1 = 1 \text{ , } a_2 = 1 \\ a_{n+2} = a_{n+1} - a_n \text{ , } n = 1 \text{ , } 2 \text{ , } 3 \text{ ,...} \end{cases}$$

គេតាងស្វ៊ីតចំនួនកុំផ្លិច $z_n = a_{n+1} - \frac{1 - i\sqrt{3}}{2} a_n$ ។

ក. ចូរស្រាយថា $z_{n+1} = \frac{1 + i\sqrt{3}}{2} z_n$ ចំពោះគ្រប់ $n \geq 1$ ។

ខ. ចូរដាក់ $\frac{1 + i\sqrt{3}}{2}$ ជាទម្រង់ត្រីកោណមាត្ររួចទាញរក $z_n$ ជាអនុគមន៍

នៃ $n$ ។

គ. ទាញរកតួទូទៅនៃស្វ៊ីត $a_n$ ។ តើ $(a_n)$ ជាស្វ៊ីតខួបឬទេ ?

## ដំណោះស្រាយ

ក. ស្រាយថា $z_{n+1} = \frac{1 + i\sqrt{3}}{2} z_n$ ចំពោះគ្រប់ $n \geq 1$

គេមាន $z_n = a_{n+1} - \frac{1 - i\sqrt{3}}{2} a_n$

គេបាន $z_{n+1} = a_{n+2} - \frac{1 - i\sqrt{3}}{2} a_{n+1}$

ដោយ $a_{n+2} = a_{n+1} - a_n$

គេបាន $z_{n+1}=a_{n+1}-a_n-\frac{1-i\sqrt{3}}{2}a_{n+1}$

$$=\frac{1+i\sqrt{3}}{2}a_{n+1}-a_n$$

$$=\frac{1+i\sqrt{3}}{2}(a_{n+1}-\frac{2}{1+i\sqrt{3}}a_n)$$

$$=\frac{1+i\sqrt{3}}{2}(a_{n+1}-\frac{1-i\sqrt{3}}{2}a_n)$$

ដូចនេះ $z_{n+1}=\frac{1+i\sqrt{3}}{2}z_n$ ។

ខ. ដាក់ $\frac{1+i\sqrt{3}}{2}$ ជាទម្រង់ត្រីកោណមាត្រ :

គេបាន $\frac{1+i\sqrt{3}}{2}=\frac{1}{2}+i\frac{\sqrt{3}}{2}=\cos\frac{\pi}{3}+i\sin\frac{\pi}{3}$

ទាញរក $z_n$ ជាអនុគមន៍នៃ $n$ :

ដោយ $z_{n+1}=\frac{1+i\sqrt{3}}{2}z_n$ នោះ $(z_n)$ ជាស្វ៊ីតធរណីមាត្រនៃចំនួន

កុំផ្លិចដែលមានរេសុង $q=\frac{1+i\sqrt{3}}{2}=\cos\frac{\pi}{3}+i\sin\frac{\pi}{3}$

និងតួ $z_1=a_2-\frac{1-i\sqrt{3}}{2}a_1=\frac{1+i\sqrt{3}}{2}=\cos\frac{\pi}{3}+i\sin\frac{\pi}{3}$

តាមរូបមន្ត $z_n = z_1 \times q^{n-1} = (\cos\frac{\pi}{3} + i\sin\frac{\pi}{3})^n$

តាមរូបមន្តដឺម័រគេបាន $z_n = \cos\frac{n\pi}{3} + i\sin\frac{n\pi}{3}$ ។

គ. ទាញរកតួទូទៅនៃស្វ៊ីត $a_n$

គេមាន $z_n = a_{n+1} - \frac{1 - i\sqrt{3}}{2} a_n$

គេបាន $z_n = (a_{n+1} - \frac{a_n}{2}) + i\frac{\sqrt{3}}{2} a_n \quad (1)$

ដោយ $z_n = \cos\frac{n\pi}{3} + i.\sin\frac{n\pi}{3} \quad (2)$

តាមទំនាក់ទំនង $(1) \& (2)$ គេបាន $\frac{\sqrt{3}}{2} a_n = \sin\frac{n\pi}{3}$

ដូចនេះ $a_n = \frac{2}{\sqrt{3}} \sin\frac{n\pi}{3}$ ។

ហើយ $(a_n)$ ជាស្វ៊ីតខួបដែលមានខួប $p = \frac{2\pi}{\frac{\pi}{3}} = 6$ ។

## លំហាត់ទី២១

គេឱ្យស្វ៊ីតនៃចំនួនកុំផ្លិច $(z_n)$ កំណត់ដោយ :

$$z_1 = \frac{2+\sqrt{3}+i}{2} \text{ និង } z_{n+1} = \frac{\sqrt{3}+i}{2} z_n + \frac{2-\sqrt{3}-i}{2}$$

ដែល $n = 1, 2, 3, \ldots$ ។

ក. តាង $w_n = z_n - 1$ ។ បង្ហាញថា $(w_n)$ ជាស្វ៊ីតធរណីមាត្រនៃចំនួនកុំផ្លិច រួចគណនា $w_n$ ជាអនុគមន៍នៃ $n$ ដោយសរសេរលទ្ធផលជាទម្រង់ត្រីកោណមាត្រ ។

ខ. ទាញបង្ហាញថា $z_n = 2\cos\frac{n\pi}{12}(\cos\frac{n\pi}{12} + i\sin\frac{n\pi}{12})$ ។

## ដំណោះស្រាយ

ក. បង្ហាញថា $(w_n)$ ជាស្វ៊ីតធរណីមាត្រនៃចំនួនកុំផ្លិច :

គេមាន $w_n = z_n - 1$

គេបាន $w_{n+1} = z_{n+1} - 1$

$$= \frac{\sqrt{3}+i}{2} z_n + \frac{2-\sqrt{3}-i}{2} - 1$$

$$= \frac{\sqrt{3}+i}{2}(z_n - 1) = \frac{\sqrt{3}+i}{2} w_n$$

ដូចនេះ $(w_n)$ ជាស្វ៊ីតធរណីមាត្រនៃចំនួនកុំផ្លិច ។

គណនា $w_n$ ជាអនុគមន៍នៃ $n$ :

គេបាន $w_n = w_1 \times q^{n-1}$

ដោយ $w_1 = \frac{\sqrt{3}+i}{2} = \cos\frac{\pi}{6} + i\sin\frac{\pi}{6}$

និង $q = \frac{\sqrt{3}+i}{2} = \cos\frac{\pi}{6} + i\sin\frac{\pi}{6}$

គេបាន $w_n = (\cos\frac{\pi}{6} + i\sin\frac{\pi}{6})^n$

ដូចនេះ $w_n = \cos\frac{n\pi}{6} + i\sin\frac{n\pi}{6}$ (រូបមន្តដឺម័រ)

ខ. ទាញបង្ហាញថា $z_n = 2\cos\frac{n\pi}{12}(\cos\frac{n\pi}{12} + i\sin\frac{n\pi}{12})$

គេមាន $w_n = z_n - 1$ នោះ $z_n = 1 + w_n$

$$z_n = 1 + \cos\frac{n\pi}{6} + i\sin\frac{n\pi}{6}$$

$$= 2\cos^2\frac{n\pi}{12} + 2i.\sin\frac{n\pi}{12}\cos\frac{n\pi}{12}$$

$$= 2\cos\frac{n\pi}{12}(\cos\frac{n\pi}{12} + i\sin\frac{n\pi}{12})$$

ដូចនេះ $z_n = 2\cos\frac{n\pi}{12}(\cos\frac{n\pi}{12} + i\sin\frac{n\pi}{12})$ ។

## លំហាត់ទី២២

គេឱ្យស្វ៊ីតនៃចំនួនពិត $(u_n)$ និង $(v_n)$ កំណត់ដោយ :

$$\begin{cases} u_1 = \dfrac{\sqrt{2}}{2} \\ v_1 = \dfrac{\sqrt{2}}{2} \end{cases} \text{ និង } \begin{cases} u_{n+1} = \dfrac{u_n - v_n}{\sqrt{2}} \\ v_{n+1} = \dfrac{u_n + v_n}{\sqrt{2}} \end{cases} \text{ ដែល } n \geq 1$$

ក. គេពិនិត្យស្វ៊ីតនៃចំនួនកុំផ្លិច $z_n = u_n + i.v_n$ ។

ចូរស្រាយថា $(z_n)$ ជាស្វ៊ីតធរណីមាត្រនៃចំនួនកុំផ្លិច រួចគណនា $z_n$ ជាអនុគមន៍នៃ $n$ ដោយសរសេរលទ្ធផលជាទម្រង់ត្រីកោណមាត្រ ។

ខ. សំដែង $u_n$ និង $v_n$ ជាអនុគមន៍នៃ $n$ ។

## ដំណោះស្រាយ

ក. ស្រាយថា $(z_n)$ ជាស្វ៊ីតធរណីមាត្រនៃចំនួនកុំផ្លិច :

គេមាន $z_n = u_n + i.v_n$

គេបាន $z_{n+1} = u_{n+1} + i.v_{n+1}$

$$= \frac{u_n - v_n}{\sqrt{2}} + i.\frac{u_n + v_n}{\sqrt{2}}$$

$$= \frac{\sqrt{2} + i\sqrt{2}}{2}(u_n + iv_n) = \frac{\sqrt{2} + i\sqrt{2}}{1} z_n$$

ដូចនេះ$(z_n)$ ជាស្វ៊ីតធរណីមាត្រនៃចំនួនកុំផ្លិច ។

គណនា $z_n$ ជាអនុគមន៍នៃ $n$ :

គេបាន $z_n = z_1 \times q^{n-1}$

តែ $z_1 = u_1 + iv_1 = \frac{\sqrt{2}}{2} + i\frac{\sqrt{2}}{2} = \cos\frac{\pi}{4} + i.\sin\frac{\pi}{4}$

និង $q = \frac{\sqrt{2}}{2} + i\frac{\sqrt{2}}{2} = \cos\frac{\pi}{4} + i.\sin\frac{\pi}{4}$

គេបាន $z_n = (\cos\frac{\pi}{4} + i\sin\frac{\pi}{4})^n$

ដូចនេះ $z_n = \cos\frac{n\pi}{4} + i.\sin\frac{n\pi}{4}$ (រូបមន្តដឺម័រ)

ខ. សំដែង $u_n$ និង $v_n$ ជាអនុគមន៍នៃ $n$

គេមាន $z_n = u_n + i.v_n$

ដោយ $z_n = \cos\frac{n\pi}{4} + i.\sin\frac{n\pi}{4}$

ដូចនេះ $u_n = \cos\frac{n\pi}{4}$ និង $v_n = \sin\frac{n\pi}{4}$ ។

## លំហាត់ទី២៣

គេឱ្យស្វ៊ីតនៃចំនួនពិត $(u_n)$ និង $(v_n)$ កំណត់ដោយ :

$$\begin{cases} u_0 = 1 \\ v_0 = \sqrt{3} \end{cases} \quad \text{និង} \quad \begin{cases} u_{n+1} = u_n^2 - v_n^2 \\ v_{n+1} = 2u_n v_n \end{cases} \quad \text{ដែល } n \geq 0$$

ក. គេពិនិត្យស្វ៊ីតនៃចំនួនកុំផ្លិច $z_n = u_n + i.v_n$ ។

ចូរស្រាយថា $z_{n+1} = z_n^2$ រួចទាញថា $z_n = z_0^{2^n}$ ។

ខ. សំដែង $u_n$ និង $v_n$ ជាអនុគមន៍នៃ $n$ ។

## ដំណោះស្រាយ

ក.ស្រាយថា $z_{n+1} = z_n^2$ រួចទាញថា $z_n = z_0^{2^n}$ :

គេមាន $z_n = u_n + i.v_n$

គេបាន $z_{n+1} = u_{n+1} + iv_{n+1}$

$$= u_n^2 - v_n^2 + 2iu_n v_n$$

$$= u_n^2 + 2iu_n v_n + (iv_n)^2$$

$$= (u_n + iv_n)^2$$

ដូចនេះ $z_{n+1} = z_n^2$ ។

ម្យ៉ាងទៀតបើ $n=0$ នោះ $z_1 = {z_0}^2$

បើ $n=1$ នោះ $z_2 = {z_1}^2 = {z_0}^4$

បើ $n=2$ នោះ $z_3 = {z_2}^2 = {z_0}^8$

ឧបមាថាវាពិតដល់តួទី $k$ គឺ $z_k = {z_0}^{2^k}$

យើងនឹងស្រាយថាវាពិតដល់តួទី $k+1$ គឺ $z_{k+1} = {z_0}^{2^{k+1}}$

គេមាន $z_{k+1} = {z_k}^2$ តែតាមការឧបមា $z_k = {z_0}^{2^k}$

គេបាន $z_{k+1} = ({z_0}^{2^k})^2 = {z_0}^{2^{k+1}}$ ពិត ។

ដូចនេះ $z_n = {z_0}^{2^n}$ ។

ខ. សំដែង $u_n$ និង $v_n$ ជាអនុគមន៍នៃ $n$

គេមាន $z_n = {z_0}^{2^n}$ ដោយ $z_0 = u_0 + iv_0 = 1 + i\sqrt{3}$

$$= 2(\cos\frac{\pi}{3} + i\sin\frac{\pi}{3})$$

គេបាន $z_n = 2^{2^n}(\cos\frac{\pi}{3} + i\sin\frac{\pi}{3})^{2^n}$

$$= 2^{2^n}(\cos\frac{2^n\pi}{3} + i\sin\frac{2^n\pi}{3})$$

ដូចនេះ $u_n = 2^{2^n}\cos\frac{2^n\pi}{3}$ ; $v_n = 2^{2^n}\sin\frac{2^n\pi}{3}$ ។

## លំហាត់ទី២៤

គេឱ្យស្វ៊ីតនៃចំនួនពិត $(I_n)$ កំណត់ដោយ :

$$I_0=\int_0^1\frac{dx}{1+e^x}\ ,\ I_1=\int_0^1\frac{e^x dx}{1+e^x},...,I_n=\int_0^1\frac{e^{nx}}{1+e^x}.dx$$

ដែល $n$ ជាចំនួនគត់ធម្មជាតិ ។

ក. គណនា $I_0+I_1;I_1$ រួចទាញរកតម្លៃនៃ $I_0$ ។

ខ. គណនា $I_n+I_{n+1}$ ជាអនុគមន៍នៃ $n$ រួចទាញរកតម្លៃ $I_2$ និង $I_3$ ។

គ. ចំពោះ $x\in[0,1]$ ចូរប្រៀបធៀបតម្លៃ $e^{nx}$ និង $e^{(n+1)x}$ ។

បង្ហាញថា $(I_n)$ ជាស្វ៊ីតកើន ដោយមិនចាំបាច់គណនា $I_n$ ។

ឃ. បង្ហាញថាចំពោះគ្រប់ $x\in[0,1]$ គេមាន $\frac{1}{4}\le\frac{1}{1+e^x}\le\frac{1}{2}$

រួចទាញរកកន្សោមអមនៃ $I_n$ តាមការគណនា $\int_0^1 e^{nx}.dx$ ។

តើស្វ៊ីត $(I_n)$ មានលីមីតឬទេ ?

## ដំណោះស្រាយ

ក. គណនា $I_0+I_1;I_1$ រួចទាញរកតម្លៃនៃ $I_0$

គេបាន $I_0+I_1=\int_0^1\frac{dx}{1+e^x}+\int_0^1\frac{e^x dx}{1+e^x}$

$$I_0+I_1=\int_0^1\frac{(1+e^x)}{1+e^x}.dx=\int_0^1 dx=1-0=1$$

ដូចនេះ $I_0+I_1=1$ ។

គេបាន $I_1=\int_0^1\frac{e^x}{1+e^x}.dx=\int_0^1\frac{(1+e^x)'.dx}{1+e^x}$

$$=\left[\ln(1+e^x)\right]_0^1=\ln(1+e)-\ln 2=\ln(\frac{1+e}{2})$$

ដូចនេះ $I_1=\ln(\frac{1+e}{2})$ ។

ហើយ $I_0=1-I_1=1-\ln(\frac{1+e}{2})=\ln(\frac{2e}{1+e})$ ។

ខ. គណនា $I_n+I_{n+1}$ ជាអនុគមន៍នៃ $n$ រួចទាញរកតម្លៃ $I_2$ និង $I_3$

គេមាន $I_n=\int_0^1\frac{e^{nx}}{1+e^x}.dx$ និង $I_{n+1}=\int_0^1\frac{e^{(n+1)x}}{1+e^x}.dx$

គេបាន $I_{n+1}+I_n=\int_0^1\frac{e^{nx}+e^{(n+1)x}}{1+e^x}.dx=\int_0^1 e^{nx}dx$

$$=\left[\frac{1}{n}e^{nx}\right]_0^1=\frac{e^n-1}{n}\ ;\ n\neq 0$$

ដូចនេះ $I_n+I_{n+1}=\frac{e^n-1}{n}$ ចំពោះគ្រប់ $n\geq 1$ ។

បើ $\mathbf{n=1}$ គេបាន $\mathbf{I_1+I_2=e-1}$ ដោយ $\mathbf{I_1=\ln(\frac{1+e}{2})}$

គេបាន $\mathbf{I_2=e-1-\ln(\frac{e+1}{2})}$ ។

បើ $\mathbf{n=2}$ គេបាន $\mathbf{I_2+I_3=\frac{e^2-1}{2}}$

គេទាញ $\mathbf{I_3=\frac{e^2-1}{2}-(e-1)+\ln(\frac{e+1}{2})}$

ដូចនេះ $\mathbf{I_3=\frac{(e-1)^2}{2}+\ln(\frac{e+1}{2})}$ ។

គ. ប្រៀបធៀបតម្លៃ $\mathbf{e^{nx}}$ និង $\mathbf{e^{(n+1)x}}$

គេមាន $\mathbf{e^{(n+1)x}-e^{nx}=e^{nx}(e^x-1)}$

ចំពោះ $\mathbf{x\in[0,1]}$ គេមាន $\mathbf{e^{nx}>0}$ និង $\mathbf{e^x-1\geq 0}$

គេបាន $\mathbf{e^{(n+1)x}-e^{nx}=e^{nx}(e^x-1)\geq 0}$

ដូចនេះ $\mathbf{e^{(n+1)x}\geq e^{nx}}$ ។

បង្ហាញថា $\mathbf{(I_n)}$ ជាស្វ៊ីតកើន ដោយមិនចាំបាច់គណនា $\mathbf{I_n}$ :

ដោយ $\mathbf{e^{(n+1)x}\geq e^{nx}}$ គ្រប់ $\mathbf{x\in[0,1]}$ គេបាន :

$\mathbf{\frac{e^{(n+1)x}}{1+e^x}\geq\frac{e^{nx}}{1+e^x}}$ នោះ $\mathbf{\int_0^1\frac{e^{(n+1)x}}{1+e^x}.dx\geq\int_0^1\frac{e^{nx}}{1+e^x}.dx}$

ដូចនេះ $\mathbf{I_{n+1}\geq I_n}$ នាំឱ្យ $\mathbf{(I_n)}$ ជាស្វ៊ីតកើន ។

ឃ. បង្ហាញថាចំពោះគ្រប់ $x\in[0,1]$ គេមាន $\frac{1}{4}\le\frac{1}{1+e^{x}}\le\frac{1}{2}$

ចំពោះ $x\in[0,1]$ គេបាន $2\le 1+e^{x}\le 1+e\le 4$

គេទាញបាន $\frac{1}{4}\le\frac{1}{1+e^{x}}\le\frac{1}{2}$ ។

ទាញរកកន្សោមអមនៃ $I_n$ តាមការគណនា $\int_0^1 e^{nx}.dx$ :

ដោយ $\frac{1}{4}\le\frac{1}{1+e^{x}}\le\frac{1}{2}$ នោះ $\frac{1}{4}e^{nx}\le\frac{e^{nx}}{1+e^{x}}\le\frac{1}{2}e^{nx}$

$$\int_0^1 \frac{1}{4}e^{nx}dx\le\int_0^1 \frac{e^{nx}}{1+e^{x}}.dx\le\int_0^1 \frac{1}{2}e^{nx}.dx$$

ដូចនេះ $\frac{e^{n}-1}{4n}\le I_n\le\frac{e^{n}-1}{2n}$ គ្រប់ $n\ge 1$ ។

ដោយ $\lim\limits_{n\to+\infty}\frac{e^{n}-1}{n}=+\infty$ នោះ $\lim\limits_{n\to+\infty}I_n=+\infty$ ។

## លំហាត់ទី២៥

គេឱ្យស្វ៊ីត $I_n = \int_0^1 \frac{x^n}{1+x+x^2}.dx$ ដែល $n \geq 0$

ក. បង្ហាញថា $(I_n)$ ជាស្វ៊ីតចុះ ។

ខ. គណនា $I_n + I_{n+1} + I_{n+2}$ ជាអនុគមន៍នៃ $n$ ។

គ. ចូរស្រាយថា $\frac{1}{3(n+1)} \leq I_n \leq \frac{1}{3(n-1)}$ ចំពោះ $n \geq 2$

រួចរក $\lim\limits_{n\to+\infty} nI_n$ ។

## ដំណោះស្រាយ

ក. បង្ហាញថា $(I_n)$ ជាស្វ៊ីតចុះ

គ្រប់ $x \in [0,1]$ គេមាន $x^{n+1} \leq x^n$

ចែកអង្គទាំងពីរនឹង $1+x+x^2 > 0$ គេបាន :

$$\frac{x^{n+1}}{1+x+x^2} \leq \frac{x^n}{1+x+x^2}$$

$$\int_0^1 \frac{x^{n+1}}{1+x+x^2}.dx \leq \int_0^1 \frac{x^n}{1+x+x^2}.dx$$

$$I_{n+1} \leq I_n$$

ដូចនេះ $(I_n)$ ជាស្វ៊ីតចុះ ។

ខ. គណនា $I_n + I_{n+1} + I_{n+2}$ ជាអនុគមន៍នៃ $n$

$$I_n + I_{n+1} + I_{n+2} = \int_0^1 \frac{x^n + x^{n+1} + x^{n+2}}{1+x+x^2}.dx$$

$$= \int_0^1 \frac{x^n(1+x+x^2)}{1+x+x^2}.dx$$

$$= \int_0^1 x^n.dx$$

$$= \left[\frac{x^{n+1}}{n+1}\right]_0^1 = \frac{1}{n+1}$$

ដូចនេះ $I_n + I_{n+1} + I_{n+2} = \dfrac{1}{n+1}$ ។

គ.ស្រាយថា $\dfrac{1}{3(n+1)} \le I_n \le \dfrac{1}{3(n-1)}$ រួចរក $\lim\limits_{n\to+\infty} nI_n$

ដោយ $(I_n)$ ជាស្វ៊ីតចុះនោះចំពោះគ្រប់ $n \ge 2$ គេមាន

$$I_n + I_{n+1} + I_{n+2} \le 3I_n \le I_{n-2} + I_{n-1} + I_n$$

$$\frac{1}{n+1} \le 3I_n \le \frac{1}{n-1}$$

ដូចនេះ $\dfrac{1}{3(n+1)} \le I_n \le \dfrac{1}{3(n-1)}$ និង $\lim\limits_{n\to+\infty} nI_n = \dfrac{1}{3}$ ។

## លំហាត់ទី២៦

គណនាអាំងតេក្រាល $\mathbf{I=\int_0^{\pi} x\sin x\cos^6 x.dx}$

## ដំណោះស្រាយ

គណនា $\mathbf{I=\int_0^{\pi} x\sin x\cos^6 x.dx}$

តាង $\mathbf{x=\pi-t}$ នោះ $\mathbf{dx=-dt}$

ចំពោះ $\mathbf{x=0}$ គេបាន $\mathbf{t=\pi}$

ចំពោះ $\mathbf{x=\pi}$ គេបាន $\mathbf{t=0}$

អាំងតេក្រាលអាចសរសេរ :

$$\mathbf{I=\int_{\pi}^{0}(\pi-t)\sin(\pi-t)\cos^6(\pi-t)(-dt)}$$

$$\mathbf{I=\int_0^{\pi}(\pi-t)\sin t\cos^6 tdt=\pi\int_0^{\pi}\sin t\cos^6 tdt-I}$$

$$\mathbf{2I=\pi\int_0^{\pi}\sin t\cos^6 tdt=\pi\left[-\frac{1}{7}\cos^7 t\right]_0^{\pi}=\frac{2\pi}{7}}$$

ដូចនេះ $\mathbf{I=\frac{\pi}{7}}$ ។

## លំហាត់ទី២៧

គណនាអាំងតេក្រាល $I=\int_0^1 \frac{x^2-1}{x^4+1}.dx$

## ដំណោះស្រាយ

គណនា $I=\int_0^1 \frac{x^2-1}{x^4+1}.dx$

គេបាន $I=\int_0^1 \frac{x^2-1}{x^4+1}.dx=\int_0^1 \frac{x^2(1-\frac{1}{x^2})}{x^2(x^2+\frac{1}{x^2})}.dx$

$$=\int_0^1 \frac{(x+\frac{1}{x})'}{(x+\frac{1}{x})^2-(\sqrt{2})^2}.dx=\left[\frac{1}{2\sqrt{2}}\ln\left|\frac{x+\frac{1}{x}-\sqrt{2}}{x+\frac{1}{x}+\sqrt{2}}\right|\right]_0^1$$

$$=\left[\frac{1}{2\sqrt{2}}\ln\left|\frac{x^2-x\sqrt{2}+1}{x^2+x\sqrt{2}+1}\right|\right]_0^1=\frac{1}{2\sqrt{2}}\ln(\frac{2-\sqrt{2}}{2+\sqrt{2}})$$

ដូចនេះ $I=\frac{1}{\sqrt{2}}\ln(\sqrt{2}-1)$ ។

## លំហាត់ទី២៨

គេឱ្យអាំងតេក្រាល $I_n = \int_0^a \frac{x^4 dx}{x^n + a^n}$ ដែល $a > 0$ ។

កំណត់ $n$ ដើម្បីឱ្យ $I_n$ មិនអាស្រ័យនឹង $a$ រួចគណនា $I_n$ ចំពោះតម្លៃនៃ $a$ ដែលបានរកឃើញខាងលើ ។

## ដំណោះស្រាយ

កំណត់ $n$ ដើម្បីឱ្យ $I_n$ មិនអាស្រ័យនឹង $a$

គេមាន $I_n = \int_0^a \frac{x^4 dx}{x^n + a^n}$ ដែល $a > 0$

តាង $x = at$ នោះ $dx = a.dt$

បើ $x = 0$ នោះ $t = 0$ និង បើ $x = a$ នោះ $t = 1$

គេបាន $I_n = \int_0^1 \frac{(at)^4.adt}{(at)^n + a^n} = a^{5-n} \int_0^1 \frac{t^4.dt}{t^n + 1}$

